# مدرسة اهل البيت

# សាលា អាស់លុល-បៃត៍

## សៀវភៅ គួរអាន (اَلْقُرْآنُ) ថ្នាក់ទី ១

(អាយុ ៥-៦ ឆ្នាំ)

قَالَ اَلنَّبِيُّ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ : طَلَبُ اَلْعِلْمِ فَرِيضَةٌ عَلَى كُلِّ مُسْلِمٍ وَ مُسْلِمَةٍ (بحار الأنوار ج ١ ص ١٧٧)

ព្រះសាស្តាﷺមានព្រះវចនៈថា៖ "ស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចលើមុស្លីមប្រុសស្រីគ្រប់រូប ។"

## សិក្សាសាសនា

# اَلْقُرْآنُ



ឈ្មោះខ្ញុំ . . . . . . . . . . . . . . . . . . .

ឈ្មោះខ្ញុំសរសេរជាភាសាអារ៉ាប់ . . . . . . . . . . . . .

# បញ្ជីមាតិកា


មេរៀនទី ១ អារម្ភបទ និង ការគោរពព្រះមហាគម្ពីរគួរអាន ........................................ ៥
មេរៀនទី ២ ហ៊ូរុហ្វ (អាលិហ្វ), នូកត៌ ........................................ ៨
មេរៀនទី ៣ ហ៊ូរុហ្វ បាអ៊៍ តាអ៊៍ សាអ៊៍ ........................................ ១២
មេរៀនទី ៤ ហ៊ូរុហ្វ ឃីម ហាអ៊៍ ខ៉អ៊៍ ........................................ ១៦
មេរៀនទី ៥ ហ៊ូរុហ្វ ដាល់ សាល់ រ៉អ៊៍ សែន៍ ........................................ ២០
មេរៀនទី ៦ ហ៊ូរុហ្វ ស៊ីន ស៊ីន សដ្វ់ ដដ្វ់ ........................................ ២៤
មេរៀនទី ៧ ហ៊ូរុហ្វ ត៏អ៊៍ ស៏អ៊៍ អ៊ីន គ៊ីន ........................................ ២៨
មេរៀនទី ៨ ហ៊ូរុហ្វ ហ្វាអ៊៍ កហ្វ់ កាហ្វ់ ........................................ ៣១
មេរៀនទី ៩ ហ៊ូរុហ្វ ឡាំ មីម នូន ........................................ ៣៥
មេរៀនទី ១០ ហ៊ូរុហ្វ វ៉ៅ ហាអ៊៍ ហាំសាស់ យ៉ាអ៊៍ ........................................ ៣៨
មេរៀនទី ១១ រៀនសាឡើងវិញ ........................................ ៤២
មេរៀនទី ១២ ការផ្គុំអក្សរ ........................................ ៤៥
មេរៀនទី ១៣ ការផ្គុំអក្សរ ........................................ ៤៨
មេរៀនទី ១៤ ការផ្គុំអក្សរ ........................................ ៥១
មេរៀនទី ១៥ ការផ្គុំអក្សរ ........................................ ៥៤
មេរៀនទី ១៦ ការផ្គុំអក្សរ ........................................ ៥៧
មេរៀនទី ១៧ ការផ្គុំអក្សរ ........................................ ៦០
មេរៀនទី ១៨ ការផ្គុំអក្សរ ........................................ ៦៣
មេរៀនទី ១៩ ការផ្គុំអក្សរ ........................................ ៦៦
មេរៀនទី ២០ ការផ្គុំអក្សរ ........................................ ៦៩

**មេរៀនទី ១**

# អារម្ភបទ

## ព្រះមហាគម្ពីរគួរអានគឺអ្វី ?

ព្រះមហាគម្ពីរគួរអានគឺសៀវភៅ ឬ តម្រា ដែលមានចារនូវព្រះរាជបន្ទូល (គឺសម្ដី) របស់អល់ឡោះហ៊្ ។

## អ្នកណាតែងព្រះមហាគម្ពីរគួរអានឡើង ?

មិនមានអ្នកណាតែងព្រះគម្ពីរគួរអានឡើងទេ ។ អល់ឡោះហ៊្បានបញ្ជូនពាក្យពេជន៍មកឲ្យព្រះសាស្ដា (ណាប៊ី) តាមរយៈទេវតាឈ្មោះយ៉ីបរ៉អ៊ីល ។

បន្ទាប់មកព្រះសាស្ដាបានសូត្រព្រះរាជឱង្ការ (អាយ៉ាត់) ប្រាប់មនុស្ស ។ មនុស្សភាគច្រើនចងចាំព្រះរាជឱង្ការរត់មាត់ តែព្រះសាស្ដាបានចាត់តាំងមនុស្សពីរបីនាក់ដើម្បីសរសេរព្រះឱង្ការទុក ។

## ព្រះមហាគម្ពីរគួរអានត្រូវសរសេរជាភាសាអ្វី ?

ព្រះគម្ពីរគួរអានត្រូវសរសេរឡើងជាភាសាអារ៉ាប់ ។ ភាសាអារ៉ាប់សរសេរពីខាងស្ដាំមកខាងឆ្វេង ។

## អល់ឡោះហ៊្មានព្រះរាជបន្ទូលថាអ្វីនៅក្នុងព្រះមហាគម្ពីរគួរអាន ?

អល់ឡោះហ៊្រៀបរាប់ប្រាប់នូវរឿងពិតរបស់ព្រះសាស្ដានានា ។
អល់ឡោះហ៊្ប្រាប់អំពីទង្វើដែលយើងត្រូវធ្វើ ។
អល់ឡោះហ៊្រៀបរាប់ប្រាប់យើងឲ្យដឹងអំពីឋានសួគ៌និងឋាននរក ។
អល់ឡោះហ៊្រៀបរាប់ប្រាប់យើងច្រើនរឿងណាស់ ។ យើងនឹងយល់រឿងមួយចំនួនពេលយើងធំបន្តិច ។ យើងនឹងយល់រឿងឯទៀតលុះត្រាយើងត្រឡប់ទៅឯ

ព្រះអង្គﷻវិញ ព្រះអង្គﷻនឹងពន្យល់ប្រាប់យើង ។

# ការគោរពព្រះមហាគម្ពីរគួរអាន

យើងត្រូវថែទាំព្រះមហាគម្ពីរគួរអានព្រោះវាជាសៀវភៅពិសេស ។ តើអ្នកត្រូវធ្វើម្តេច ?

យើងត្រូវកាន់ ចាប់ ឬប៉ះព្រះមហាគម្ពីរគួរអានដោយសេចក្តីគោរព (គ្រូត្រូវបង្ហាញសិស្ស) ។

យើងមិនត្រូវបើកព្រះមហាគម្ពីរគួរអានចោលជាដាច់ខាត បើពុំមានអ្នកណាសូត្រទេនោះ ។

យើងមិនត្រូវប៉ះតួអក្សរ (ហ៊្វរុហ្វ اَلْحُرُوف) ព្រះមហាគម្ពីរគួរអានទេ បើពុំទាន់បានយកទឹកវូឌុអ៍ជាមុនសិនទេនោះ ។ គេអាចសូត្រ (ឬអាន) ព្រះមហាគម្ពីរគួរអានបានដោយមិនប៉ះតួអក្សរ ឬដោយដាក់សន្លឹកផ្លាស្ទិចថ្លាទ្រាប់ពីលើសន្លឹកទំព័រព្រះមហាគម្ពីរគួរអាននោះបាន ។

ស្ងៀមស្ងាត់ (អល់ឡោះហ្ទ៍ﷻសព្វព្រះហឫទ័យបើព្យាយាមធ្វើ) ពេលសូត្រព្រះមហាគម្ពីរគួរអាន គឺ៖
-គ្របក្បាល - ដោយមួកម្យ៉ាង(កន្តឹប)សម្រាប់ប្រុស ដោយក្រណាត់ទទូរក្បាលសម្រាប់ស្រី ។
-បែរមុខទៅរកគិបឡាត់ពេលគេសូត្រព្រះមហាគម្ពីរគួរអាន ។

យើងសូត្រថា អាអ៊ូស៊្ហូ ប៊ិលឡាហ៊ី មីណាស្ហ៍ស្ហៃត៏នីរ៉ូយ៊ីម (أَعُوذُ بِاللَّهِ مِنَ الشَّيْطَانِ الرَّجِيمِ) និងប៊ិសមិលឡាហ៊ី រ៉ោះហ្ម៉ានីរ៉ហ៊ីម (بِسْمِ اللهِ الرَّحْمٰنِ الرَّحِيمِ) មុនចាប់ផ្តើមសូត្រព្រះមហាគម្ពីរគួរអាន ។

# ការអនុវត្តិ ១

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមអក្សរ និងយល់ន័យរបស់

أَعُوذُ بِاللَّهِ مِنَ اَلشَّيْطَانِ اَلرَّجِيمِ

*ខ្ញុំសូមជ្រកកោនក្រោមព្រះជម្រកអល់ឡោះហ្ល៍عز وجلឲ្យចាកផុតមារសៃតនلعنه اللهត្រូវបណ្ដាសា*

២) ចូរអ្នកយកសន្លឹកផ្លាស្ទិចថ្លាមួយបន្ទះមកអនុវត្តិការប្រើប្រាស់ ហើយចូរដឹងថាហេតុអ្វីគេធ្វើបែបនេះ ។

៣) ចូរផាត់ពណ៌រូបក្នុងទំព័រទី ៣ គឺរូបត្ថ៍លិបសូត្រគួរអានខាងលើ ហើយសរសេរឈ្មោះអ្នក (លោក/អ្នកគ្រូសរសេរឈ្មោះសិស្សជាភាសាអារ៉ាប់) ។

**មេរៀនទី ២**

# ហ៊្វូរុហ្វ (اَلْحُرُوف តួអក្សរ)

ដូចភាសាខ្មែរយើងបេះបិទដែរ ក ខ គ ឃ ង ... ជាតួអក្សរនៃព្យញ្ជនៈខ្មែរ ឯ ...ا ب ت ជាហ៊្វូរុហ្វ (តួអក្សរ) នៃព្យញ្ជនៈអារ៉ាប់ ។

ហ៊្វូរុហ្វដំបូងបង្អស់ដែលយើងសិក្សាគឺ អាលិហ្វ (اليف ) ។

ا

**នូក្តុ ឬ នីក្តុ** (ចំណុច)

នូក្តុ ឬ នីក្តុ (نُقَط ឬ نِقَاط ជាពហុវចនៈរបស់សព្ទ នុក្តោះតុ៏ (نُقْطَة)) ប្រែថាចំណុច គឺចំណុចដែលមាននៅពីលើឬពីក្រោមតួអក្សរមួយចំនួនក្នុងភាសាអារ៉ាប់ ។

ក្នុងភាសាអារ៉ាប់មានតួអក្សរខ្លះដែលស្រដៀងគ្នា ដែលអាចខុសគ្នាបានអាស្រ័យលើចំនួននិងកន្លែងនូក្តុ (ចំណុចមួយឬពីរពីលើឬពីក្រោម) ។

ឧទាហរណ៍ ب ت ث ប្រៀបបាននឹងអក្សរបារាំង b d p q ដែលខុសគ្នាត្រង់កន្លែងមានជើងឬសក់ (ពោលគឺ ជើងឬសក់ពីលើឬពីក្រោម) ។

# ការអនុវត្តិ ២

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមអក្សរ និងយល់ន័យរបស់

بِسْمِ اَللهِ اَلرَّحْمٰنِ اَلرَّحِيمِ

*ដោយនូវព្រះនាមអល់ឡោះហ្ទ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណា*

*ប្រណី*

(សូមមើលសៀវភៅហ្វីកោះហ្វ៍ថ្នាក់ទី ១ មេរៀនទី ២)

២) ចូរចាប់ផ្តើមធ្វើលំហាត់ ១ (ហាត់សរសេរអក្សរ អាលិហ្វ ខាងក្រោមនេះ) ។

៣) ចូរធ្វើលំហាត់ ២ (ហាត់ដាក់នុក្កត្ត) ចូរកុំភ្លេចចំណាំសរសេរពីខាងស្តាំទៅខាងឆ្វេង ។ សំខាន់បំផុតគឺ ក្នុងភាសាអារ៉ាប់មិនមានចំណុចបីនៅពីក្រោមហ្វ៊ុរុហ្វទេ ។

**លំហាត់ ១**

# អាលិហ្វ





## លំហាត់ ២

# នូក្កត្ត់

ចូរដាក់នុក្កតោ្តត៍មួយពីលើបន្ទាត់

ចូរដាក់នុក្កតោ្តះត៍មួយពីក្រោមបន្ទាត់

ចូរដាក់នូក្កត្ត់ពីរពីលើបន្ទាត់

ចូរដាក់នូក្កត្ត់ពីរពីក្រោមបន្ទាត់

ចូរដាក់នូក្កត្ត់បីពីលើបន្ទាត់

**មេរៀនទី ៣**

# ហ៊ួរុហ្វ បាអ៊ុ តាអ៊ុ ស្ញាអ៊ុ

តទៅនេះយើងសិក្សាហ៊្វរុហ្វ (អក្សរ) ដែលមានសណ្ឋានដូចទូក ង

ٮ

គេអាចបង្កើតតួអក្សរបីទៀតបានជាមួយរូបសណ្ឋានទូក ង នេះដោយដាក់នូក្ដត់ ។ ដាក់នុក្ដតោះត៍ពីខាងក្រោមរូបទូកងនេះ គេបង្កើតបាននូវតួអក្សរ បាអ៊ុ (ب (باء)) ។ ដាក់នូក្ដត់ពីរពីលើរូបទូកងនេះ គេបង្កើតបាននូវតួអក្សរ តាអ៊ុ (ت (تاء)) ។ ដាក់នូក្ដត់បីពីលើរូបទូកងនេះ គេបង្កើតបាននូវតួអក្សរ ស្ញាអ៊ុ (ث (ثاء) ដើម្បីថាឲ្យត្រឹមត្រូវតាមសម្លេងវា ត្រូវថាដោយបញ្ចេញអណ្ដាតតាមចន្លោះធ្មេញលើនិងធ្មេញក្រោមបន្តិច) ។

# ការអនុវត្ត ៣

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមសម្លេងអក្សរ និងយល់ន័យរបស់

اَلْحَمْدُ لِلّٰهِ رَبِّ الْعٰلَمِيْنَ

*សូមថ្វាយសេចក្ដីសរសើរចំពោះអល់ឡោះហ៍ﷻ ព្រះម្ចាស់ពិភពទាំងពួង*

(លោក/អ្នកគ្រូគប្បីពន្យល់អំពីការប្រើប្រាស់សម្ដីមួយឃ្លានេះ ឧទាហរណ៍ ពេលគេបានចប់រួចរាល់ពីការងារអ្វីមួយ ឬពេលគេបានឃើញអ្វីមួយដែលអស្ចារ្យ ។ល ។)

២) ចូរឲ្យសិស្សរាល់គ្នាថាសាឡើងសាចុះ ។

៣) ចូរធ្វើលំហាត់ ៣ ខាងក្រោមនេះ ដោយថាសាចុះឡើងហ្វ៊ូរុហ្វទាំងបីតួព្រមនឹងសរសេរ (ពីស្តាំទៅឆ្វេង) ។

៤) ចូរធ្វើលំហាត់ ៤ (បាអ៊ុំ តាអ៊ុំ ស្ញាអ៊ុំ / នូក្ខត្ញុំ) ពីស្តាំទៅឆ្វេង ។

**លំហាត់ ៣**

# បាអ៊ុ តាអ៊ុ សាអ៊ុ

ចូរផាត់ពណ៌ហ្វូរុបៗ ហើយសរសេរព្រមនឹងថាឲ្យចាំរត់មាត់ ។



ب ب ب

ت ت ت

ث ث ث

## លំហាត់ ៤

ចូរដាក់នូក្ខត់ឲ្យត្រូវចំនួនដើម្បីបង្កើតតួអក្សរហ្ញ៊ុហ្វនីមួយៗ

| | | |
|---|---|---|
| ٮ | ٮ | ٮ |
| ស្ថាអ៊ុ | តាអ៊ុ | បាអ៊ុ |
| ٮ | ٮ | ٮ |
| តាអ៊ុ | បាអ៊ុ | ស្ថាអ៊ុ |
| ٮ | ٮ | ٮ |
| បាអ៊ុ | តាអ៊ុ | ស្ថាអ៊ុ |
| ٮ | ٮ | ٮ |
| បាអ៊ុ | ស្ថាអ៊ុ | តាអ៊ុ |

## មេរៀនទី ៤

ចូរអ្នករៀនសាឡើងវិញហ៊្វរុហ្វទាំងអម្បាលម៉ានដែលបានរៀនរួចមកហើយ ។

តទៅនេះយើងសិក្សាហ៊្វរុហ្វ (អក្សរ) ដែលមានសណ្ឋានដូចអក្សរ C បារាំងដែលមានគំនូសផ្តេកតូចពីលើ ។

ح

គេអាចបង្កើតតួអក្សរអារ៉ាប់បីទៀតបានជាមួយរូបសណ្ឋាន C នេះដោយដាក់នូក្តត្ដ់ ។

ដោយមិនដាក់នុក្តត្ដោះត៏ទេ គេបង្កើតបាននូវតួអក្សរ ហ៊ាអ៊ (ح (حاء) ថាដោយត្បៀតដើមកបន្តិច) ។

ដោយដាក់នុក្តត្ដោះត៏មួយចំកណ្តាល ح នេះ គេបង្កើតបាននូវតួអក្សរ ឃ៊ីម (ج (جيم)) ។

ដោយដាក់នុក្តត្ដោះត៏មួយពីលើ ح នេះ គេបង្កើតបាននូវតួអក្សរ ខ៊ អ៊ (خ (خاء) ថាដោយត្បៀតដើមកបន្តិច)

# ការអនុវត្តិ ៤

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមសម្លេងអក្សរ និងយល់ន័យរបស់

الرَّحْمٰنِ الرَّحِيْمِ

*ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី*

២) ចូរឲ្យសិស្សគ្រប់គ្នាថាសាចុះសាឡើង ។

៣) ចូរធ្វើលំហាត់ ៥ ខាងក្រោមនេះ ។ ថាសាចុះសាឡើងហ្វ៊ុរុហ្វទាំងបីតួព្រម នឹងសរសេរ (ពីស្តាំទៅឆ្វេងដដែល) ។

៤) ចូរធ្វើលំហាត់ ៦ (ឃ៊ឹម ហ្វ៊ាអ៊ុំ ខ៊ុំអ៊ុំ) ពីស្តាំទៅឆ្វេង ។

## លំហាត់ ៥

ចូរផាត់ពណ៌នូក្កត្ត់ ។

ج ح

خ

ج ج ج

ح ح ح

خ خ خ

## លំហាត់ ៦

ចូរគូសខ្វែងលើហ្វ៊ារុហ្វដែលមិនត្រឹមត្រូវ ។

| | | | |
|---|---|---|---|
| خ | خ | ح | ج |
| ឃ៊ីម | ខ៍អ៊ុ | ហាអ៊ុ | ហាអ៊ុ |
| ج | ح | خ | ج |
| ឃ៊ីម | ខ៍អ៊ុ | ខ៍អ៊ុ | ឃ៊ីម |
| خ | ح | ج | ح |
| ហាអ៊ុ | ឃ៊ីម | ហាអ៊ុ | ខ៍អ៊ុ |
| ح | ج | خ | خ |
| ខ៍អ៊ុ | ហាអ៊ុ | ឃ៊ីម | ខ៍អ៊ុ |

**មេរៀនទី ៥**

ចូរអ្នករៀនសាឡើងវិញហ៊្វូរុហ្វទាំងអម្បាលម៉ានដែលបានរៀនរួចមកហើយ ។

តទៅនេះយើងសិក្សាហ៊្វូរុហ្វ (អក្សរ) គូ មួយមាននុក្ធតោះត៍ មួយទៀតមិនមាននុក្ធតោះត៍ទេ ។

មិនដាក់នុក្ធតោះត៍ទេ គឺហ៊្វូរុហ្វ ដ្ញាល់ د ((دال) បញ្ចេញអណ្តាតតាមចន្លោះធ្មេញលើនិងធ្មេញក្រោមបន្តិច) ។

ដាក់នុក្ធតោះត៍មួយពីលើគឺហ៊្វូរុហ្វ ស្នាល់ ذ ((ذال) បញ្ចេញអណ្តាតតាមចន្លោះធ្មេញលើនិងធ្មេញក្រោមបន្តិច) ។

មិនដាក់នុក្ធតោះត៍ទេ គឺហ៊្វូរុហ្វ រ៉អ៊ុ ر (راء) ។

ដាក់នុក្ធតោះត៍មួយពីលើគឺហ៊្វូរុហ្វ ស្សៃន៍ ز (زين) ។

# ការអនុវត្ត ៥

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមសម្លេងអក្សរ និងយល់ន័យរបស់

مَالِكِ يَوْمِ الدِّيْنِ

*ព្រះម្ចាស់នៃថ្ងៃជំនុំជម្រះ*

២) ចូរឲ្យសិស្សគ្រប់គ្នាថាសាចុះសាឡើង ។

៣) ចូរធ្វើលំហាត់ ៧ (ដ្ញាល់ ស្នាល់ រ៉អ៊ុ ស្សៃន៍) ។ ថាសាចុះសាឡើងគ្រប់ហ៊្វូរុហ្វព្រមនឹងសរសេរ (ពីស្តាំទៅឆ្វេងដដែល) ។ ចូរផាត់ពណ៌នុក្ធត ។

៨) ចូរធ្វើលំហាត់ ៨ (ដ្វាល់ ស្វាល់ រ៉អ៊ុ ស្រៃន៍) ពីស្តាំទៅឆ្វេង ។

**លំហាត់ ៧**

# ហ៊្វូរុហ្វ ដ្ទាល់ ស្ទាល់ រ៉អ៊ុ ស្ទៃន៍

ذْ دْ

زْ رْ

د د د

ذ ذ ذ

ر ر ر

ز ز ز

## លំហាត់ ៨

ចូរផាត់ពណ៌រថយន្ត ។ រថយន្ត ដ្ញាល់ ដាក់ពណ៌ក្រហម ។ រថយន្ត ស្ញាល់ ដាក់ពណ៌លឿង ។ រថយន្ត រ៉អ៊ ដាក់ពណ៌ផ្ទៃមេឃ ។ រថយន្ត ស៊្រែន៍ ដាក់ពណ៌បៃតង ។



## មេរៀនទី ៦

ចូរអ្នករៀនសាឡើងវិញហ៊្វរុហ្វទាំងអម្បាលម៉ានដែលបានរៀនរួចមកហើយ ។

តទៅនេះយើងសិក្សាហ៊្វរុហ្វ (អក្សរ) គូ មួយមាននុក្ទតោះត៍ មួយទៀតមិនមាននុក្ទតោះត៍ទេ ។

ហ៊្វរុហ្វមួយហាក់ដូចជាមានធ្មេញពីរ គឺៈ

# س

មិនដាក់នុក្ទតោះត៍ទេគឺហ៊្វរុហ្វ ស៊ីន **س** (سين) ។

ដាក់នុក្ទត៍បីពីលើគឺហ៊្វរុហ្វ ស៊្ហីន **ش** (شين) ។

មិនដាក់នុក្ទតោះត៍ទេ គឺហ៊្វរុហ្វ ស្វដ់ **ص** (صاد) ។

ដាក់នុក្ទតោះត៍មួយពីលើ គឺហ៊្វរុហ្វ ដ្វដ់ **ض** (ضاد) ។

## ការអនុវត្តិ ៦

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមសម្លេងអក្សរ និងយល់ន័យរបស់

إِيَّاكَ نَعْبُدُ وَإِيَّاكَ نَسْتَعِيْنُ

*ព្រះអង្គទេដែលអស់ទូលព្រះបង្គំជាខ្ញុំគោរពបូជា ព្រះអង្គទេដែលអស់ទូលព្រះ*

*បង្គំជាខ្ញុំអង្វរសូមនូវជំនួយ ។*

២) ចូរឲ្យសិស្សគ្រប់គ្នាថាសាចុះសាឡើង ។
៣) ចូរធ្វើលំហាត់ ៧ (ដ្ទាល់ ស្ទាល់ រ៉ ស្ទែ) ដោយថាសាចុះសាឡើងគ្រប់ហ្វ៊ូរុហ្វព្រម
នឹងសរសេរ (ពីស្តាំទៅឆ្វេងដដែល) ។
៤) ចូរធ្វើលំហាត់ ៩ (ស៊ីន ស្ទ៊ីន ស្វដ្ទ ដ្វដ្ទ) ។ ថាឈ្មោះហ្វ៊ូរុហ្វសាចុះសាឡើងព្រម
នឹងសរសេរ (ពីស្តាំទៅឆ្វេង) ។ ចូរផាត់ពណ៌ានូក្ទត្ទ ។
៥) រួចហើយធ្វើលំហាត់ ១០ ។

## លំហាត់ ៩

# ស៊ីន ស៊ីន សដ់ ដដ់

س ش

ص ض

س س س

ش ش ش

ص ص ص

ض ض ض

**លំហាត់ ១០**

ចូរគូសភ្ជាប់ឈ្មោះហ្វ៊ូរុហ្វឲ្យត្រូវនឹងតួហ្វ៊ូរុហ្វ ។

| | |
|---|---|
| س | ស៊ីន |
| ش | ដ៉ដ៉្ដ (ض) |
| ص | ស៊ីន (ش) |
| ض | ស្វដ៉្ដ (ص) |
| ش | ស្វដ៉្ដ (ص) |
| ص | ស៊ីន (ش) |
| ض | ដ៉ដ៉្ដ (ض) |

## មេរៀនទី ៧

ចូរអ្នករៀនសាឡើងវិញហ្វ៊ូរុហ្វទាំងអម្បាលម៉ានដែលបានរៀនរួចមកហើយ ។

តទៅនេះយើងសិក្សាហ្វ៊ូរុហ្វ (អក្សរ) គូ មួយមាននុក្ហតោះត៍ មួយទៀតមិនមាននុក្ហតោះត៍ទេ ។ ط គូនឹង ظ, ع គូនឹង غ ។

មិនដាក់នុក្ហតោះត៍ទេគឺហ្វ៊ូរុហ្វ ត៍អ៊ ط (طَاء) ។
ដាក់នុក្ហតោះត៍មួយពីលើគឺហ្វ៊ូរុហ្វ ស៍អ៊ ظ (ظَاء) ។

មិនដាក់នុក្ហតោះត៍ទេគឺហ្វ៊ូរុហ្វ អ៊ីន (عِين) ع (ថាដោយត្បៀតដើមកបន្តិច) ។
ដាក់នុក្ហតោះត៍មួយពីលើគឺហ្វ៊ូរុហ្វ គ៊ីន (غين) غ(ថាដោយត្បៀតដើមកបន្តិច) ។

# ការអនុវត្ត ៧

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមសម្លេងអក្សរ និងយល់ន័យរបស់

اِهْدِنَا الصِّرَاطَ الْمُسْتَقِيْمَ

*សូមព្រះអង្គមេត្តាដឹកនាំអស់ទូលព្រះបង្គំជាខ្ញុំឆ្ពោះទៅកាន់មាគ៌ាត្រង់ត្រូវ ។*

២) ចូរឲ្យសិស្សគ្រប់គ្នាថាសាចុះសាឡើង ។
៣) ចូរធ្វើលំហាត់ ១១ (ត៍អ៊ ស៍អ៊ អ៊ីន គ៊ីន) ។ ថាសាចុះសាឡើងគ្រប់ហ្វ៊ូរុហ្វព្រមនឹងសរសេរ (ពីស្តាំទៅឆ្វេង) ។ ចូរផាត់ពណ៌នូក្ហត់ ។
៤) ចូរធ្វើលំហាត់ ១២ (ត៍អ៊ ស៍អ៊ អ៊ីន គ៊ីន) ពីស្តាំទៅឆ្វេង ។

## លំហាត់ ១១

# ط ظ

# ع غ

ط ط ط

ظ ظ ظ

ع ع ع

غ غ غ

**លំហាត់ ១២**

ចូរសរសេរតួអក្សរដំបូងបង្អស់របស់ឈ្មោះអ្នកពេញលើរូបសត្វ ។



ក្ងោក طَاوُوْس

ប្រើស ظَبِي



ខ្យាដំរី عَقْرَبْ





ក្អែក غُراب

## មេរៀនទី ៨

ចូរអ្នករៀនសាឡើងវិញហ្វ៊ូរុហ្វទាំងអម្បាលម៉ានដែលបានរៀនរួចមកហើយ ។

តទៅនេះយើងសិក្សាហ្វ៊ូរុហ្វ (អក្សរ) ដែលមានសណ្ឋានដូចរូបទូកងដែរតែមាន ក្បាលមូល ។

ដាក់នុក្ខតោះត្ត័មួយពីលើគឺហ្វ៊ូរុហ្វ ហ្វាអ៊ុ ف (فاء) ។

ហ្វ៊ូរុហ្វដែលមានសណ្ឋានដូចទូកដែលមានបាតជ្រៅ ដាក់នុក្ខតោះពីរពីលើ គឺហ្វ៊ូរុហ្វ ក្វហ្វ ق (قاف) មានសម្លេងដើមក ។

ហ្វ៊ូរុហ្វមួយទៀតដែលមានសម្លេងស្រដៀង ក្វហ្វ ដែរតែស្រាលជាងបន្តិច គឺហ្វ៊ូរុហ្វ កាហ្វ ك (كاف) ។

# ការអនុវត្តិ ៨

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមសម្លេងអក្សរ និងយល់ន័យរបស់

صِرَاطَ الَّذِيْنَ أَنْعَمْتَ عَلَيْهِمْ

*មាគ៌ារបស់បណ្តាអ្នកដែលព្រះអង្គបានព្រះរាជទានឲ្យនូវឧបការធម៌*

២) ចូរឲ្យសិស្សគ្រប់គ្នាថាសាចុះសាឡើង ។
៣) ចូរធ្វើលំហាត់ ១៣ (ហ្វាអ៊ុ ក្វហ្វ កាហ្វ) ។ ថាសាចុះសាឡើងគ្រប់ហ្វ៊ូរុហ្វព្រមនឹងសរសេរ (ពីស្តាំទៅឆ្វេង) ។ ចូរផាត់ពណ៌នុក្ខតោះ ។

៤) ចូរធ្វើលំហាត់ ១៤ (ហ្វាអ៊ុ កូហ្វ កាហ្វ) ពីស្តាំទៅឆ្វេង ។

**លំហាត់ ១៣**

## ហ្វាអ៊ុ កួហ្វ់ កាហ្វ់

# ف ق

# ك

ف ف ف

ق ق ق

ك ك ك

## លំហាត់ ១៤




ចូរផាត់ពណ៌ប៊ឹតប៉ោងហ្វ៊ូរុហ្វ
- ហ្វាអ៊ុ៍ ពណ៌ក្រហម
- កួហ៊្វ ពណ៌ផ្ទៃមេឃ
- កាហ៊្វ ពណ៌លឿង

**មេរៀនទី ៩**

ចូរអ្នករៀនសាឡើងវិញហ៊្វរុហ្វទាំងអម្បាលម៉ានដែលបានរៀនរួចមកហើយ ។

តទៅនេះយើងសិក្សាហ៊្វរុហ្វ (អក្សរ) បីតួគឺ៖

-ហ៊្វរុហ្វឡាំ ل (لام) ។

-ហ៊្វរុហ្វ មីម م (ميم) ។

-ហ៊្វរុហ្វ នូន ن (نون) មានសណ្ឋានដូចទូកងបាតជ្រៅតែមាននុក្កតោះតួមួយពីលើ ។

# ការអនុវត្តិ ៩

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមសម្លេងអក្សរ និងយល់ន័យរបស់

غَيْرِ الْمَغْضُوْبِ عَلَيْهِمْ

*ពុំមែនបណ្តាអ្នកដែលទទួលរងនូវព្រះពិរោធទេ*

២) ចូរឲ្យសិស្សគ្រប់គ្នាថាសាចុះសាឡើង ។

៣) ចូរធ្វើលំហាត់ ១៥ (ឡាំ មីម នូន) ។ ថាសាចុះសាឡើងគ្រប់ហ៊្វរុហ្វព្រមនឹងសរសេរ (ពីស្តាំទៅឆ្វេង) ។ ចូរផាត់ពណ៌ហ៊្វរុហ្វធំ ។

៤) ចូរធ្វើលំហាត់ ១៦ (ឡាំ មីម នូន) ពីស្តាំទៅឆ្វេង ។

**លំហាត់ ១៥**

## ឡាំ មីម នូន






## លំហាត់ ១៦

ចូរផាត់ពណ៌ផ្កាយដូចពណ៌លោកខែដែរ ។ រួចហើយចូរគូសភ្ជាប់ឈ្មោះហ្វ៊ូរុហ្វ ជាមួយតួហ្វ៊ូរុហ្វឲ្យត្រូវគ្នា ។



## មេរៀនទី ១០

ចូរអ្នករៀនសាឡើងវិញហ៊្វរុហ្វទាំងអម្បាលម៉ានដែលបានរៀនរួចមកហើយ ។

តទៅនេះយើងសិក្សាហ៊្វរុហ្វ (អក្សរ) បួនតួគឺ៖

-វ៉ៅ و (واو) ។

-ហ្ហាអ៊ុ ه (هاء) ។

-ហ្ហាំស្សាស់ ء (هَمْزة) ។

-យ៉ាអ៊ុ ي (ياء) មានន្ទុក្ខត្ថពីរពីក្រោម ។

# អនុវត្ត ១០

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមសម្លេងអក្សរ និងយល់ន័យរបស់

وَلَا الضَّآلِّيْنَ

*ហើយក៏ពុំមែនបណ្តាអ្នកវង្វេងខុសទេដែរ*

២) ចូរឲ្យសិស្សគ្រប់គ្នាថាសាចុះសាឡើង ។

៣) ចូរធ្វើលំហាត់ ១៧ (វ៉ៅ ហ្ហាអ៊ុ ហ្ហាំស្សាស់ យ៉ាអ៊ុ) ។ ថាសាចុះសាឡើងគ្រប់ហ៊្វរុហ្វព្រមនឹងសរសេរ (ពីស្តាំទៅឆ្វេង) ។

៤) ចូរធ្វើលំហាត់ ១៨ (វ៉ៅ ហ្វាអ៊ុំ ហ្វាំស្មាស្ញុំ យ៉ាអ៊ុំ) ពីស្ដាំទៅឆ្វេងជានិច្ច ។

**លំហាត់ ១៧**

# វ៉ៅ ហាអ៊៍ ហាំសាស់ យ៉ាអ៊៍

ء ه و

ي

و

ه

ء

ي

## លំហាត់ ១៨

ស្ទូចត្រីត្រូវនឹងសន្ទូច (គូសខ្សែពីឈ្មោះហ្វ៊ូរុហ្វទៅភ្ជាប់នឹងត្រីស៊ីតួហ្វ៊ូរុហ្វ) ។



**មេរៀនទី ១១**

មេរៀននេះមានគោលបំណងពិនិត្យមើលថាសិស្សទាំងអស់គ្នាស្គាល់និងចាំរត់មាត់ហ្វូរុហ្វទាំងអស់នៃព្យញ្ជនៈអារ៉ាប់ដោយមិនបាច់មានគេជួយប្រាប់ ។

សិស្សទាំងអស់គ្នាត្រូវអាចអានហ្វូរុហ្វទាំងអស់បានយ៉ាងស្ទាត់ឥតខុស ។

ចូរធ្វើលំហាត់ ១៩ - ព្យញ្ជនៈអារ៉ាប់, លំហាត់ ២០ - សិក្សាឲ្យចាំស៊ូរ៉ោះត៍ អាល់-ហ្វាទីហាស់ ។

បើសិស្សណាស្គាល់ហ្វូរុហ្វទាំងអស់ បានធ្វើលំហាត់ ១៩ ត្រឹមត្រូវមិនខុស គេអាចប្រគល់ **សញ្ញាបត្រ អាស់សាស៊ូរ៉អ៊ុ គួរអាន ១** ឲ្យសិស្សនោះ ។
បើសិស្សមិនជាប់សញ្ញាបត្រ អាស់សាស៊ូរ៉អ៊ុ គួរអាន ១ ទេ ត្រូវផ្ញើសំបុត្រទៅឪពុកម្តាយសិស្សដោយបញ្ជាក់ថាហ្វូរុហ្វណាមួយដែលសិស្សនោះមិនស្គាល់ ឬមិនចងចាំច្បាស់ ឲ្យឪពុកម្តាយត្រូវជួយវា ។

សេចក្តីសំបុត្រគឺ៖
"យើងខ្ញុំបានបង្ហាត់បង្រៀនកូនលោកអ្នកនូវហ្វូរុហ្វទាំងអស់នៃព្យញ្ជនៈអារ៉ាប់ តែកូនលោកអ្នកមិនទាន់ស្គាល់ច្បាស់ហ្វូរុហ្វខ្លះនៅឡើយពេលប្រលង ។ ហ្វូរុហ្វទាំងនោះគឺ៖

(រាយឈ្មោះហ្វូរុហ្វដែលសិស្សមិនទាន់ចាំស្ទាត់)

សូមលោកឪពុកអ្នកម្តាយជួយណែនាំកូនឲ្យចេះព្យញ្ជនៈទាំងអស់សម្រាប់អាទិត្យក្រោយ ជាពិសេសហ្វូរុហ្វរាយឈ្មោះខាងលើនេះ ដើម្បីនឹងទទួលបាននូវសញ្ញាបត្រ អាស់សាស៊ូរ៉អ៊ុ គួរអាន ១ ។

جَزَاكَ ٱللَّٰهُ"

## លំហាត់ ១៩

ចូរសរសេរតួអក្សរហ៊្វរុហ្វឲ្យត្រូវនឹងឈ្មោះវា ។

អាលិហ្វ
បាអ៊ុ៍
តាអ៊ុ៍
ស្ទាអ៊ុ៍
យ៉ីម
ហ្ទាអ៊ុ៍
ខ៉ំអ៊ុ៍
ដ្វាល់
ស្ទាល់
រ៉អ៊ុ៍
ស្ៃន៍
ស៊ីន
ស្ទីន
ស្វដ្វំ
ដ្វដ្វំ

ត៏អ៊ុ៍
ស៏អ៊ុ៍
អ៊ីន
គ៊ីន
ហ្វាអ៊ុ៍
ក្វហ្វ៉
កាហ្វ៉
ឡាំ
មីម
នូន
វ៉ៅ
ហ្វាអ៊ុ៍
ហ្វាំស្ទាស្វ៉
យ៉ាអ៊ុ៍

**លំហាត់ ២០**

# ស៊ូរ៉ោះតុ៍ អាល់-ហ្វាទីហាស្ញ

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيمِ

اَلْحَمْدُ لِلّٰهِ رَبِّ الْعَالَمِيْنَ

الرَّحْمٰنِ الرَّحِيْمِ

مَالِكِ يَوْمِ الدِّيْنِ

إِيَّاكَ نَعْبُدُ وَإِيَّاكَ نَسْتَعِيْنُ

اهْدِنَا الصِّرَاطَ الْمُسْتَقِيْمَ

صِرَاطَ الَّذِيْنَ أَنْعَمْتَ عَلَيْهِمْ

غَيْرِ الْمَغْضُوْبِ عَلَيْهِمْ وَلَا الضَّالِّيْنَ

## មេរៀនទី ១២

# ការផ្គុំអក្សរ

ក្នុងភាសាអារ៉ាប់ ពេលហ៊្វរុហ្វជាប់គ្នា ចុងបំផុត (កន្ទុយ) របស់ហ៊្វរុហ្វត្រូវកាត់ចោល (លើកលែងហ៊្វរុហ្វចុងបំផុត) ។ គេអាចប្រៀបធៀបរបៀបសរសេរនេះបាននឹងតួអក្សរធំនិងតួអក្សរតូចក្នុងភាសាបារាំង (ឧទាហរណ៍ I - i) ។

គេចែកហ៊្វរុហ្វជាក្រុមដើម្បីស្រួលចាំរបៀបផ្គុំតួហ៊្វរុហ្វជាប់គ្នាឲ្យកើតជាពាក្យ ។ ក្រុមដំបូងគឺក្រុមហ៊្វរុហ្វដែលមានសណ្ឋានដូចទូកងគឺៈ

ب ت ث

គេកាត់ហ៊្វរុហ្វទាំងនេះចំពាក់កណ្ដាល គេដាក់នូក្កត្ត់ (ចំណុច) ពីលើឬពីក្រោមខ្សែបញ្ឈរ (មើលគំរូខាងក្រោមនេះ) ។



| ចុងពាក្យ | កណ្ដាលពាក្យ | ដើមពាក្យ | ហ៊្វរុហ្វពេញតួ |
|---|---|---|---|
| ـب | ـبـ | بـ | ب |
| ـت | ـتـ | تـ | ت |
| ـث | ـثـ | ثـ | ث |

# អនុវត្តិ ១២

១) ចូរទន្ទេញឲ្យចាំរត់មាត់ស្វរ៉ោះត៍ អាល់-ហ្វាទីហ៊ាស្ទ់ (លំហាត់ ២០) ។

២) ចូរអានមួយឃ្លាខាងក្រោមនេះ ។

بتثتثبثبتبتتتبتبثتبتبثبثتث

(កុមារត្រូវអានបានដោយពុំមានគេប្រាប់)

៣) ធ្វើលំហាត់ ២១ ថាសាចុះសាឡើងព្រមនឹងសរសេរអក្សររាល់តួអក្សរ (ពីស្តាំទៅឆ្វេង) ។

## លំហាត់ ២១

ចូរគូសខ្សែកាត់ហ៊្វូរុហ្វ រួចហើយគូសខ្វែងជើងក្អែកលើប៉ែកដែលគេចោល ។

ب ت ث

ចូរបំពេញតារាងខាងក្រោមនេះ ។

| ចុងពាក្យ | កណ្ដាលពាក្យ | ដើមពាក្យ | ហ៊្វូរុហ្វពេញតួ |
|---|---|---|---|
| | | | ب |
| | | | ت |
| | | | ث |

ចូរផ្គុំហ៊្វូរុហ្វទាំងអស់ភ្ជាប់គ្នា ហើយដាក់ភ្ជាប់ពីក្រោយរថភ្លើងរូបរថភ្លើង ។

ب ت ث ت ث ب



## មេរៀនទី ១៣

ក្នុងភាសាអារ៉ាប់ ពេលហ្វ៊ូរុហ្វជាប់គ្នា ចុងបំផុត (កន្ទុយ) របស់ហ្វ៊ូរុហ្វត្រូវកាត់ចោល (លើកលែងហ្វ៊ូរុហ្វចុងបំផុត) ។ គេអាចប្រៀបធៀបរបៀបសរសេរនេះបាននឹងតួអក្សរធំនិងតួអក្សរតូចក្នុងភាសាបារាំង (ឧទាហរណ៍ I - *i*) ។

គេចែកហ្វ៊ូរុហ្វជាក្រុមដើម្បីស្រួលចាំរបៀបផ្គុំតួហ្វ៊ូរុហ្វភ្ជាប់គ្នាឲ្យកើតជាពាក្យ ។ ថ្ងៃនេះយើងសិក្សាហ្វ៊ូរុហ្វមួយក្រុមដែលស្រដៀងហ្វ៊ូរុហ្វដែលមានសណ្ឋានដូចទូក ង គឺ៖

ي ن

ហ្វ៊ូរុហ្វទាំងពីរតួនេះផ្លាស់ទៅជាមានសណ្ឋានពាក់កណ្ដាលទូកងជាមួយនុក្តត់ ។

يـ ← ي    نـ ← ن

| ចុងពាក្យ | កណ្ដាលពាក្យ | ដើមពាក្យ | ហ្វ៊ូរុហ្វពេញតួ |
|---|---|---|---|
| ـن | ـنـ | نـ | ن |
| ـي | ـيـ | يـ | ي |

## អនុវត្តិ ១៣

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមសម្លេងអក្សរ និងយល់ន័យរបស់

قُلْ هُوَ اللَّهُ أَحَدٌ

*ចូរអ្នកថា៖ "ព្រះអង្គគឺអល់ឡោះហ្ន៍ ព្រះមួយគត់ ។*

២) ចូរអានមួយឃ្លាខាងក្រោមនេះ ។

نيبتثينثتبنبتيثتنبيثي

(កុមារត្រូវអានបានដោយពុំមានគេប្រាប់)

៣) ធ្វើលំហាត់ ២២ ថាសាចុះសាឡើងព្រមនឹងសរសេរអក្សររាល់តួអក្សរ (ពីស្តាំទៅឆ្វេង) ។

## លំហាត់ ២២

ចូរសរសេរហ្វ៊ូរុហ្វដែលមានសណ្ឋានដូចពាក់កណ្ដាលទូកង ក្រោយពីត្រូវបានកាត់ ហើយដើម្បីផ្គុំភ្ជាប់ជាមួយហ្វ៊ូរុហ្វឯទៀត ។

ن ← ي ←

ចូរបំពេញតារាងខាងក្រោមនេះ ។

| ចុងពាក្យ | កណ្ដាលពាក្យ | ដើមពាក្យ | ហ្វ៊ូរុហ្វពេញតួ |
|---|---|---|---|
| | | | ن |
| | | | ي |

ចូរផ្គុំហ្វ៊ូរុហ្វទាំងអស់ភ្ជាប់គ្នា ហើយដាក់ភ្ជាប់ពីក្រោយរថភ្លើងរូបរថភ្លើង ។

ب ت ت ث ن ي ي ن

## មេរៀនទី ១៤

ក្នុងភាសាអារ៉ាប់ ពេលហ៊្វូរុហ្វជាប់គ្នា ចុងបំផុត (កន្ទុយ) របស់ហ៊្វូរុហ្វត្រូវកាត់ចោល (លើកលែងហ៊្វូរុហ្វចុងបំផុត) ។ គេអាចប្រៀបធៀបរបៀបសរសេរនេះបាននឹងតួអក្សរធំនិងតួអក្សរតូចក្នុងភាសាបារាំង (ឧទាហរណ៍ I - i) ។

គេចែកហ៊្វូរុហ្វជាក្រុមដើម្បីស្រួលចាំរបៀបផ្គុំតួហ៊្វូរុហ្វភ្ជាប់គ្នាឲ្យកើតជាពាក្យ ។

ថ្ងៃនេះយើងសិក្សាហ៊្វូរុហ្វមួយក្រុមដែលមានសណ្ឋានដូចទូកង តែមានក្បាលជារង្វង់មូល គឺ៖ ق ف

គេកាត់ហ៊្វូរុហ្វទាំងពីរនេះចំពាក់កណ្ដាល ។



| ចុងពាក្យ | កណ្ដាលពាក្យ | ដើមពាក្យ | ហ៊្វូរុហ្វពេញតួ |
|---|---|---|---|
| ـف | ـفـ | فـ | ف |
| ـق | ـقـ | قـ | ق |

# អនុវត្តិ ១៤

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមសម្លេងអក្សរ និងយល់ន័យរបស់

اللَّهُ الصَّمَدُ

*អល់ឡោះហ្ ព្រះអនន្តជាទីអាស្រ័យរបស់សព្វសារពើ*

២) ចូរអានមួយឃ្លាខាងក្រោមនេះ ។

فقبتشيقفينشبقيفنفتقثينتق

(កុមារត្រូវអានបានដោយពុំមានគេប្រាប់)

៣) ធ្វើលំហាត់ ២៣ ថាសាចុះសាឡើងព្រមនឹងសរសេរអក្សររាល់តួអក្សរ (ពីស្តាំទៅឆ្វេង) ។

## លំហាត់ ២៣

ចូរគូសខ្សែកាត់ហ្វូរុហ្វ រួចហើយគូសខ្វែងជើងក្អែកលើប៉ែកដែលគេចោល ។

# ف ق

ចូរបំពេញតារាងខាងក្រោមនេះ ។

| ចុងពាក្យ | កណ្តាលពាក្យ | ដើមពាក្យ | ហ្វូរុហ្វពេញតួ |
|---|---|---|---|
| | | | ف |
| | | | ق |

ចូរផ្គុំហ្វូរុហ្វទាំងអស់ភ្ជាប់គ្នា ហើយដាក់ភ្ជាប់ពីក្រោយរថភ្លើងរូបរថភ្លើង ។

# ب ت ث ن ي ف ق



## មេរៀនទី ១៥

ក្នុងភាសាអារ៉ាប់ ពេលហ្វ៊ូរុហ្វជាប់គ្នា ចុងបំផុត (កន្ទុយ) របស់ហ្វ៊ូរុហ្វត្រូវកាត់ចោល (លើកលែងហ្វ៊ូរុហ្វចុងបំផុត) ។ គេអាចប្រៀបធៀបរបៀបសរសេរនេះបាននឹងតួអក្សរធំនិងតួអក្សរតូចក្នុងភាសាបារាំង (ឧទាហរណ៍ I - i) ។

គេចែកហ្វ៊ូរុហ្វជាក្រុមដើម្បីស្រួលចាំរបៀបផ្គុំតួហ្វ៊ូរុហ្វភ្ជាប់គ្នាឲ្យកើតជាពាក្យ ។

ថ្ងៃនេះយើងសិក្សាហ្វ៊ូរុហ្វមួយក្រុម ដែលស្រដៀងក្រុមហ្វ៊ូរុហ្វដែលមានសណ្ឋានដូចទូកងដែរ មានរបៀបផ្គុំដូចក្រុមហ្វ៊ូរុហ្វដែលមានសណ្ឋានដូចទូងដែរ គឺៈ

س ش ص ض

គេកាត់ហ្វ៊ូរុហ្វទាំងពីរនេះចំពាក់កណ្ដាល ។



| ចុងពាក្យ | កណ្ដាលពាក្យ | ដើមពាក្យ | ហ្វ៊ូរុហ្វពេញតួ |
|---|---|---|---|
| ـس | ـسـ | سـ | س |
| ـش | ـشـ | شـ | ش |
| ـص | ـصـ | صـ | ص |
| ـض | ـضـ | ضـ | ض |

# អនុវត្ត ១៥

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមសម្លេងអក្សរ និងយល់ន័យរបស់

لَمْ يَلِدْ

*ព្រះអង្គមិនឲ្យកំណើតទេ*

២) ចូរអានមួយឃ្លាខាងក្រោមនេះ ។

سشصضبتثنيفقشض

(កុមារត្រូវអានបានដោយពុំមានគេប្រាប់)

៣) ធ្វើលំហាត់ ២៤ ថាសាចុះសាឡើងព្រមនឹងសរសេរអក្សររាល់តួអក្សរ (ពីស្តាំទៅឆ្វេង) ។

**លំហាត់ ២៤**

ចូរគូសខ្សែកាត់ហ្វ៊ូរុហ្វ រួចហើយគូសខ្វែងជើងក្អែកលើប៉ែកដែលគេចោល ។

ض ص ش س

ចូរបំពេញតារាងខាងក្រោមនេះ ។

| ចុងពាក្យ | កណ្ដាលពាក្យ | ដើមពាក្យ | ហ្វ៊ូរុហ្វពេញតួ |
|---|---|---|---|
| | | | س |
| | | | ش |
| | | | ص |
| | | | ض |

ចូរផ្គុំហ្វ៊ូរុហ្វទាំងអស់ភ្ជាប់គ្នា ហើយដាក់ភ្ជាប់ពីក្រោយរថភ្លើងរូបរថភ្លើង ។

ب ت ث ن ي ف ق س ش ص ض



## មេរៀនទី ១៦

ក្នុងភាសាអារ៉ាប់ ពេលហ្វ៊ូរុហ្វជាប់គ្នា ចុងបំផុត (កន្ទុយ) របស់ហ្វ៊ូរុហ្វត្រូវកាត់ចោល (លើកលែងហ្វ៊ូរុហ្វចុងបំផុត)។ គេអាចប្រៀបធៀបរបៀបសរសេរនេះបាននឹងតួអក្សរធំនិងតួអក្សរតូចក្នុងភាសាបារាំង (ឧទាហរណ៍ I - *i*)។

គេចែកហ្វ៊ូរុហ្វជាក្រុមដើម្បីស្រួលចាំរបៀបផ្គុំតួហ្វ៊ូរុហ្វភ្ជាប់គ្នាឲ្យកើតជាពាក្យ។

ថ្ងៃនេះយើងសិក្សាហ្វ៊ូរុហ្វមួយក្រុមដែលគេកាត់ផ្តេកពាក់កណ្តាល មិនកាត់បញ្ឈរទេពេលសរសេរជាប់គ្នា គឺ៖

خ ح ج

គេកាត់ហ្វ៊ូរុហ្វទាំងនេះផ្តេកពាក់កណ្តាល (⟷)។



| ចុងពាក្យ | កណ្តាលពាក្យ | ដើមពាក្យ | ហ្វ៊ូរុហ្វពេញតួ |
|---|---|---|---|
| ـج | ـجـ | جـ | ج |
| ـح | ـحـ | حـ | ح |
| ـخ | ـخـ | خـ | خ |

# អនុវត្ត ១៦

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមសម្លេងអក្សរ និងយល់ន័យរបស់

وَلَمْ يُولَدْ

*ព្រះអង្គមិនត្រូវប្រសូតមកទេ ។*

២) ចូរអានមួយឃ្លាខាងក្រោមនេះ ។

جحخبتثنيفقسشصضخ

(កុមារត្រូវអានបានដោយពុំមានគេប្រាប់)

៣) ធ្វើលំហាត់ ២៥ ថាសាចុះសាឡើងព្រមនឹងសរសេរអក្សររាល់តួអក្សរ (ពីស្តាំទៅឆ្វេង) ។

## លំហាត់ ២៥

ចូរគូសខ្សែកាត់ហ្វ៊ូរុហ្វ រួចហើយគូសខ្វែងជើងក្អែកលើប៉ែកដែលគេចោល ។

ج ح خ

ចូរបំពេញតារាងខាងក្រោមនេះ ។

| ចុងពាក្យ | កណ្ដាលពាក្យ | ដើមពាក្យ | ហ្វ៊ូរុហ្វពេញតួ |
|---|---|---|---|
| | | | ج |
| | | | ح |
| | | | خ |

ចូរផ្គុំហ្វ៊ូរុហ្វទាំងអស់ភ្ជាប់គ្នា ហើយដាក់ភ្ជាប់ពីក្រោយរថភ្លើងរូបរថភ្លើង ។

ب ت ث ن ي ف ق س ش ص ض

ج ح خ



## មេរៀនទី ១៧

ក្នុងភាសាអារ៉ាប់ ពេលហ្វ៊ូរុហ្វជាប់គ្នា ចុងបំផុត (កន្ទុយ) របស់ហ្វ៊ូរុហ្វត្រូវកាត់ចោល (លើកលែងហ្វ៊ូរុហ្វចុងបំផុត) ។ គេអាចប្រៀបធៀបរបៀបសរសេរនេះបាននឹងតួអក្សរធំនិងតួអក្សរតូចក្នុងភាសាបារាំង (ឧទាហរណ៍ I - ℓ) ។

គេចែកហ្វ៊ូរុហ្វជាក្រុមដើម្បីស្រួលចាំរបៀបផ្គុំតួហ្វ៊ូរុហ្វភ្ជាប់គ្នាឲ្យកើតជាពាក្យ ។

ថ្ងៃនេះយើងសិក្សាហ្វ៊ូរុហ្វមួយក្រុមទៀតដែលគេកាត់ផ្តេកពាក់កណ្តាល មិនកាត់បញ្ឈរទេពេលសរសេរជាប់គ្នា គឺ៖

غ ع

គេកាត់ហ្វ៊ូរុហ្វទាំងនេះផ្តេកពាក់កណ្តាល ( ⟷ ) ។



| ចុងពាក្យ | កណ្តាលពាក្យ | ដើមពាក្យ | ហ្វ៊ូរុហ្វពេញតួ |
|---|---|---|---|
| ـع | ـعـ | عـ | ع |
| ـغ | ـغـ | غـ | غ |

# អនុវត្តិ ១៧

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមសម្លេងអក្សរ និងយល់ន័យរបស់

وَلَمْ يَكُنْ لَهُ كُفُوًا أَحَدٌ

*ពុំមានអ្នកណាដូចព្រះអង្គឡើយ ។*

២) ចូរអានមួយឃ្លាខាងក្រោមនេះ ។

عغبتثنيفقسشصضجحخغ

(កុមារត្រូវអានបានដោយពុំមានគេប្រាប់)

៣) ធ្វើលំហាត់ ២៦ ថាសាចុះសាឡើងព្រមនឹងសរសេរអក្សររាល់តួអក្សរ (ពីស្តាំទៅឆ្វេង) ។

**លំហាត់ ២៦**

ចូរគូសខ្សែកាត់ហ្វ៊ូរុហ្វ រួចហើយគូសខ្វែងជើងក្អែកលើប៉ែកដែលគេចោល ។

ع غ

ចូរបំពេញតារាងខាងក្រោមនេះ ។

| ចុងពាក្យ | កណ្ដាលពាក្យ | ដើមពាក្យ | ហ្វ៊ូរុហ្វពេញតួ |
|---|---|---|---|
| | | | غ |
| | | | ع |

ចូរផ្គុំហ្វ៊ូរុហ្វទាំងអស់ភ្ជាប់គ្នា ហើយដាក់ភ្ជាប់ពីក្រោយរថភ្លើងរូបរថភ្លើង ។

ب ت ث ن ي ف ق س ش ص ض

ج ح خ ع غ



## មេរៀនទី ១៨

ក្នុងភាសាអារ៉ាប់ ពេលហ្វ៊ូរុហ្វជាប់គ្នា ចុងបំផុត (កន្ទុយ) របស់ហ្វ៊ូរុហ្វត្រូវកាត់ចោល (លើកលែងហ្វ៊ូរុហ្វចុងបំផុត) ។ គេអាចប្រៀបធៀបរបៀបសរសេរនេះបាននឹងតួអក្សរធំនិងតួអក្សរតូចក្នុងភាសាបារាំង (ឧទាហរណ៍ I - i) ។

គេចែកហ្វ៊ូរុហ្វជាក្រុមដើម្បីស្រួលចាំរបៀបផ្គុំតួហ្វ៊ូរុហ្វភ្ជាប់គ្នាឲ្យកើតជាពាក្យ ។

មានហ្វ៊ូរុហ្វខ្លះខុសពីហ្វ៊ូរុហ្វឯទៀតដែលយើងបានសិក្សាកន្លងមកហើយនោះ ។

ថ្ងៃនេះយើងសិក្សាហ្វ៊ូរុហ្វមួយក្រុមដែលជាអញ្ញត្រសព្ទ ដែលគេសរសេរផ្គុំជាមួយហ្វ៊ូរុហ្វឯទៀតដោយដាក់ជើង គឺ៖

ظ ط

ការផ្គុំភ្ជាប់ជាមួយហ្វ៊ូរុហ្វឯទៀតគឺ៖

ـظ ← ظ    ـط ← ط

| ចុងពាក្យ | កណ្ដាលពាក្យ | ដើមពាក្យ | ហ្វ៊ូរុហ្វពេញតួ |
|---|---|---|---|
| ـط | ـطـ | طـ | ط |
| ـظ | ـظـ | ظـ | ظ |

# អនុវត្តិ ១៨

១) ចូរសូត្ររត់មាត់ឲ្យត្រឹមត្រូវតាមសម្លេងអក្សរសាឡើងវិញ

**ស៊ូរ៉ោះតុ៍ អាល់-អ៊ិះខ្ល៉ាស្វ់**

بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيْمِ

قُلْ هُوَ اللَّهُ أَحَدٌ

اللَّهُ الصَّمَدُ

لَمْ يَلِدْ وَلَمْ يُولَدْ

وَلَمْ يَكُنْ لَهُ كُفُوًا أَحَدٌ

២) ចូរអានមួយឃ្លាខាងក្រោមនេះ ។

تظنتشيفقسشصضجحخعغظ

(កុមារត្រូវអានបានដោយពុំមានគេប្រាប់)

៣) ធ្វើលំហាត់ ២៧ ថាសាចុះសាឡើងព្រមនឹងសរសេរអក្សររាល់តួអក្សរ (ពីស្តាំទៅឆ្វេង) ។

**លំហាត់ ២៧**

ចូរគូសខ្សែកាត់ហ្វ៊ូរុហ្វ រួចហើយគូសខ្វែងជើងក្អែកលើប៉ែកដែលគេចោល ។

# ط ظ

ចូរបំពេញតារាងខាងក្រោមនេះ ។

| ចុងពាក្យ | កណ្ដាលពាក្យ | ដើមពាក្យ | ហ្វ៊ូរុហ្វពេញតួ |
|---|---|---|---|
| | | | ط |
| | | | ظ |

ចូរផ្គុំហ្វ៊ូរុហ្វទាំងអស់ភ្ជាប់គ្នា ហើយដាក់ភ្ជាប់ពីក្រោយរថភ្លើងរូបរថភ្លើង ។

ص ت ث ن ي ف ق س ش ض ج ب

ح خ ع غ ط ظ



# មេរៀនទី ១៩

ក្នុងភាសាអារ៉ាប់ ពេលហ៊្វរុហ្វជាប់គ្នា ចុងបំផុត (កន្ទុយ) របស់ហ៊្វរុហ្វត្រូវកាត់ចោល (លើកលែងហ៊្វរុហ្វចុងបំផុត) ។ គេអាចប្រៀបធៀបរបៀបសរសេរនេះបាននឹងតួអក្សរធំនិងតួអក្សរតូចក្នុងភាសាបារាំង (ឧទាហរណ៍ I - *i*) ។

គេចែកហ៊្វរុហ្វជាក្រុមដើម្បីស្រួលចាំរបៀបផ្គុំតួហ៊្វរុហ្វភ្ជាប់គ្នាឲ្យកើតជាពាក្យ ។

ថ្ងៃនេះយើងសិក្សាហ៊្វរុហ្វមួយក្រុមដែលផ្លាស់ប្តូររូបសណ្ឋានបន្តិចបន្តួច ពេលគេសរសេរផ្គុំជាមួយហ៊្វរុហ្វឯទៀត គឺៈ

ك ل م ه

ដូច្នេះការផ្គុំភ្ជាប់ជាមួយហ៊្វរុហ្វឯមានដូចតទៅ គឺៈ

| ចុងពាក្យ | កណ្តាលពាក្យ | ដើមពាក្យ | ហ៊្វរុហ្វពេញតួ |
|---|---|---|---|
| ـك | ـكـ | كـ | ك |
| ـل | ـلـ | لـ | ل |
| ـم | ـمـ | مـ | م |
| ـه | ـهـ | هـ | ه |

ហ្វាអ៊ុំផ្លាស់ប្តូររូបសណ្ឋានបន្តិចដើម្បីឲ្យប្លែកពីមីម ។

# អនុវត្តិ ១៩

១) ចូរសូត្ររត់មាត់ឲ្យត្រឹមត្រូវតាមសម្លេងអក្សរសាឡើងវិញ ស៊ូរ៉ោះតុ៏ អាល់-អ៊ិះខ៉្ឡាស្វ៊ (អនុវត្តិ ១៨)

២) ចូរអានមួយឃ្លាខាងក្រោមនេះ ។

كلمهبتثنيفقسشصضجحخعغطظ

(កុមារត្រូវអានបានដោយពុំមានគេប្រាប់)

៣) ធ្វើលំហាត់ ២៨ ថាសាចុះសាឡើងព្រមនឹងសរសេរអក្សររាល់តួអក្សរ (ពីស្តាំទៅឆ្វេង) ។

## លំហាត់ ២៨

ហ្វូរុហ្វមួយដែលផ្លាស់ប្តូររូបសណ្ឋានបន្តិចបន្តួចពេលគេសរសេរផ្គុំ

ك ل م ه

ចូរបំពេញតារាងខាងក្រោមនេះ ។

| ចុងពាក្យ | កណ្តាលពាក្យ | ដើមពាក្យ | ហ្វូរុហ្វពេញតួ |
|---|---|---|---|
| | | | ك |
| | | | ل |
| | | | م |
| | | | ه |

ចូរផ្គុំហ្វូរុហ្វទាំងអស់ភ្ជាប់គ្នា ហើយដាក់ភ្ជាប់ពីក្រោយរថភ្លើងរូបរថភ្លើង ។

ص ت ث ن ي ف ق س ش ض ج ب

ح خ ع غ ط ظ ك ل م ه



## មេរៀនទី ២០

ក្នុងភាសាអារ៉ាប់ ពេលហ៊្វរុហ្វជាប់គ្នា ចុងបំផុត (កន្ទុយ) របស់ហ៊្វរុហ្វត្រូវកាត់ចោល (លើកលែងហ៊្វរុហ្វចុងបំផុត) ។ គេអាចប្រៀបធៀបរបៀបសរសេរនេះបាននឹងតួអក្សរធំនិងតួអក្សរតូចក្នុងភាសាបារាំង (ឧទាហរណ៍ I - *i*) ។

ថ្ងៃនេះយើងសិក្សាហ៊្វរុហ្វមួយចំនួនទៀត ដែលស្ទើរមិនផ្លាស់ប្តូររូបសណ្ឋានតែម្តង ពេលគេសរសេរផ្គុំ ។ គេអាចហៅហ៊្វតុហ្វនោះបានថាហ៊្វរុហ្វមានៈ គឺៈ

ا د ذ ر ز و

| ចុងពាក្យ | កណ្តាលពាក្យ | ដើមពាក្យ | ហ៊្វរុហ្វពេញតួ |
|---|---|---|---|
| ـا | ▬ ـا | ▬ ا | ا |
| ـد | ▬ ـد | ▬ د | د |
| ـذ | ▬ ـذ | ▬ ذ | ذ |
| ـر | ▬ ـر | ▬ ر | ر |
| ـز | ▬ ـز | ▬ ز | ز |
| ـو | ▬ ـو | ▬ و | و |

សញ្ញា ▬ មានន័យថាហ៊្វរុហ្វមិនតទៅភ្ជាប់ជាមួយហ៊្វរុហ្វបន្ទាប់ទេ (គឺហ៊្វរុហ្វដែលនៅខាងឆ្វេង ពីព្រោះភាសាអារ៉ាប់សរសេរពីស្តាំទៅឆ្វេង) ។

# អនុវត្តិ ២០

១) ចូរអានមួយឃ្លាខាងក្រោមនេះ ។

ادذرزوثيوقذشزجرغذظا

(កុមារត្រូវអានបានដោយពុំមានគេប្រាប់)

២) ធ្វើលំហាត់ ២៩ ថាសាចុះសាឡើងព្រមនឹងសរសេរអក្សររាល់តួអក្សរ (ពីស្តាំទៅឆ្វេង) ។

៣) ធ្វើលំហាត់ ៣០ ដើម្បីរៀនសាឡើងវិញ ។

៤) ចូរចាប់ផ្តើមនាំសិស្សសូត្រស៊ូរ៉ោះត៍ អាល់-ហ្វាទិ៍ហ្ាស់ និង ស៊ូរ៉ោះត៍ អាល់-អ៊ិះខ្ល៉ាស្វ នៅក្នុងព្រះមហាគម្ពីរគួរអាន ។

**លំហាត់ ២៩**

ហ្វូរុហ្វដែលមិនភ្ជាប់នឹងហ្វូរុហ្វបន្ទាប់ គឺ៖

ا د ذ ر ز و

ចូរបំពេញតារាងខាងក្រោមនេះ ។

| ចុងពាក្យ | កណ្តាលពាក្យ | ដើមពាក្យ | ហ្វូរុហ្វពេញតួ |
|---|---|---|---|
| | | | ا |
| | | | د |
| | | | ذ |
| | | | ر |
| | | | ز |
| | | | و |

ចូរផ្គុំហ្វូរុហ្វទាំងអស់ភ្ជាប់គ្នា ហើយដាក់ភ្ជាប់ពីក្រោយរថភ្លើងរូបរថភ្លើង ។

ص ت ث ن ي ف ق س ش ض ج ب

ح خ ع غ ط ظ ك ل م ه ا د ذ ر ز

و



## លំហាត់ ៣០

ចូរគូសខ្សែប៊ឹតប៉ោង ផាត់ពណ៌ប៉ុតប៉ោងហ្វ៊ូរុហ្វដូចតទៅគឺៈ

-ហ្វ៊ូរុហ្វដែលគេកាត់បញ្ឈរពាក់កណ្ដាល ដាក់ពណ៌បៃតង ។

-ហ្វ៊ូរុហ្វដែលគេកាត់ផ្ដេកពាក់កណ្ដាល ដាក់ពណ៌ផ្ទៃមេឃ ។

-ហ្វ៊ូរុហ្វដែលមានជើងពេលសរសេរផ្គុំ ដាក់ពណ៌លឿង ។

-ហ្វ៊ូរុហ្វដែលស្ទើរតែមិនផ្លាស់ប្ដូររូបសណ្ឋានពេលសរសេរផ្គុំ ដាក់ពណ៌ទឹកក្រូច ។

-ហ្វ៊ូរុហ្វដែលមិនតភ្ជាប់ជាមួយហ្វ៊ូរុហ្វបន្ទាប់ (ហ្វ៊ូរុហ្វមានៈ) ដាក់ពណ៌ក្រហម ។




